# គម្រោងទប់ស្កាត់បញ្ហា

## នៃការមើលរឿងអាសអាភាសនៃយុវជនខ្មែរ



សម្ព័ន្ធចាប់ដៃ CHAB DAI COALITION

alongsiders INTERNATIONAL

THE MESSAGE PARLOUR សារកាហ្វេ

Boroh La-or Pit បុរសល្អពិត

aim AGAPE INT'L MISSIONS

she RESCUE HOME

# រូបភាពទី ១៖

**សាច់រឿង៖** ចាន់ត្រាជាក្មេងម្នាក់ដែលរស់នៅជាមួយគ្រួសាររបស់គាត់។ឥឡូវនេះគ្រួសាររបស់គាត់កំពុងបរិភោគអាហារថ្ងៃត្រង់ជុំគ្នា។គ្រួសាររបស់គាត់បានហៅឲ្យគាត់មកញ៉ាំបាយជាមួយតែគាត់ចង់នៅក្នុងផ្ទះ ហើយមើលទូរស័ព្ទរបស់គាត់វិញ។



## សំនួរពិភាក្សា

1. ហេតុអ្វីបានជាចាន់ត្រាចង់នៅឆ្ងាយពីគ្រួសាររបស់គាត់?
2. តើប្អូនគិតថាគ្រួសាររបស់គាត់មានអារម្មណ៍យ៉ាងណាដែរ?
3. តើប្អូនគិតថា ចាន់ត្រាគួរតែធ្វើអ្វី?

## យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីសារៈសំខាន់នៃការជជែកគ្នាលេងជាគ្រួសារ និងការបរិភោគអាហារជុំគ្នា**



## រូបភាពទី ២៖



**សាច់រឿង៖** ចាន់ត្រាមិនបានលេងកីឡាជាមួយមិត្តភ័ក្តចាស់ៗរបស់គាត់ទេ តែបែរជាមើលទស្សនាវដ្ដីអាសអាភាស ជាមួយពួកម៉ាកថ្មីៗទៅវិញ។

### សំនួរពិភាក្សា

1. តើចាន់ត្រា និងមិត្តភ័ក្តថ្មីៗរបស់គាត់បានជ្រើសរើសមិនធ្វើអ្វី ?
2. ហេតុអ្វីពួកគេចង់នៅឆ្ងាយពីអ្នកដទៃ ?
3. តើពួកគេកំពុងធ្វើការសំរេចចិត្តដែលត្រឹមត្រូវឬទេ ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីសារៈសំខាន់នៃលេងជាមួយមិត្តភ័ក្ត តាមរបៀបមួយដែលល្អ (ឧទា. ការលេងកីឡាដើម្បីកសាងទំនាក់ទំនង)**


7
Love
Rated R
18+

## រូបភាពទី ៣៖



**សាច់រឿង៖** បន្ទាប់ពីចេញពីរៀន ចាន់ត្រា និងមិត្តភ័ក្ត្ររបស់គាត់ចំណាយពេលនៅហាងហ្គេមអ៊ីនធើណិត ដើម្បីមើលរឿងអាសអាភាស។

### សំនួរពិភាក្សា

1. តើជាធម្មតា កុមារធ្វើអ្វីនៅហាងហ្គេមអ៊ីនធើណិត ?
2. តើប្អូនៗគិតថា ចាន់ត្រា និងមិត្តភ័ក្តរបស់គាត់ធ្វើការសំរេចចិត្តដែលល្អឬទេ ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីគ្រោះថ្នាក់ និងការចំណាយលុយលេងហ្គេមនៅហាងអ៊ីនធើណិត (ឧទា. លួចលុយ, ការប្រឈមក្នុងការមើលរឿងអាសអាភាស, ខ្ជះខ្ជាយពេលវេលា)**



# រូបភាពទី ៤៖

**សាច់រឿង៖** ចាន់ត្រាក៏ចាប់ផ្តើមបាត់បង់ការផ្ចង់អារម្មណ៍រៀនសូត្រនៅសាលារៀន...



## សំនួរពិភាក្សា

1. ហេតុអ្វីបានជាចាន់ត្រាមើលរឿងអាសអាភាស?
2. នៅពេលចាន់ត្រាបាត់បង់ការផ្ចង់អារម្មណ៍លើការសិក្សា តើនឹងមានផលអាក្រក់អ្វីខ្លះ?
3. តើប្អូនគិតថា មិត្តភ័ក្តរបស់ចាន់ត្រានៅខាងស្តាំដៃកំពុងគិតអ្វីពីគាត់?

## យោបល់សម្រាប់អ្នកសម្របសម្រួល

**ពិភាក្សាអំពីមូលហេតុដែលកុមារមើលរឿងអាសអាភាស និងនិយាយអំពីផលប៉ះពាល់នៃរឿងអាសអាភាសទៅលើការសិក្សា និងទំនាក់ទំនងមិត្តភាព (ឧទា. រៀនបានពិន្ទុទាប, អស់កំលាំង, អារម្មណ៍ទោសកំហុស, អារម្មណ៍មួម៉ៅនឹងខ្លួនឯង និងអ្នកដទៃ)**



## រូបភាពទី ៥៖



**សាច់រឿង៖** ...ចាន់ត្រាជក់មើលរូបភាពអាសអាភាសក្នុងទូរស័ព្ទរបស់គាត់ រហូតដល់យប់ជ្រៅ។

### សំនួរពិភាក្សា

1. តើប្អូនដឹងថាហេតុអ្វីបានជាចាន់ត្រារៀនបានពិន្ទុទាប ?
2. ហេតុអ្វីបានជាចាន់ត្រានៅតែបន្តមើលរូបភាពអាសអាភាសដូច្នេះ ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីការញៀនដែលកើតឡើងពីការមើលរឿងអាសអាភាសញឹកញាប់ ដែលអាចក្លាយជាទំលាប់អាក្រក់មួយពិបាកយកឈ្នះ**



## រូបភាពទី ៦៖

**សាច់រឿង៖** ណារីដែលជាប្អូនស្រីរបស់ចាន់ត្រា បានឃើញចាន់ត្រាកំពុងមើលរូបភាពអាសអាភាសនៅក្នុងទូរស័ព្ទ។ ណារីមានអារម្មណ៍មិនស្រួល ហើយក៏សួរចាន់ត្រាថាហេតុអ្វីបានជាមើលរឿងបែបនេះ។ ចាន់ត្រាមានភាពអាម៉ាស់ដោយសារតែគាត់ឃើញថាណារីមិនសប្បាយចិត្ត ព្រោះចាន់ត្រាស្រលាញ់ប្អូនស្រីរបស់គាត់ និងមិនចង់ធ្វើឲ្យនាងពិបាកចិត្តទេ។



### សំនួរពិភាក្សា

1. ហេតុអ្វីបានជាណារីមានអារម្មណ៍មិនស្រួល និងមិនសប្បាយចិត្ត?
2. ហេតុអ្វីបានជាចាន់តាម្រានអារម្មណ៍ខ្មាស់ណារី?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីអារម្មណ៍របស់ចាន់ត្រា ណារី និង រិទ្ធ ហើយហេតុអ្វីបានជាពួកគេមានអារម្មណ៍បែបនេះ**



## រូបភាពទី ៧៖



**សាច់រឿង៖** រិទ្ធដែលជាបងប្រុសចាន់ត្រាក៏ខ្វល់ខ្វាយចំពោះចាន់ត្រាដែរ។ គាត់បាននិយាយជាមួយចាន់ត្រាអំពីគ្រោះថ្នាក់នៃការមើលរឿងអាសអាភាស។ ចាន់ត្រាចាប់ផ្ដើមគិតអំពីរឿងទាំងអស់នេះ។

### សំនួរពិភាក្សា

1. តើការមើលរឿងអាសអាភាសមានគ្រោះថ្នាក់ និងផលអាក្រក់អ្វីខ្លះ?
2. តើការមើលរូបភាពអាសអាភាសធ្វើឲ្យប្អូនមានអារម្មណ៍យ៉ាងណាអំពីរាងកាយរបស់ខ្លួនឯង និងរាងកាយអ្នកដទៃ?
3. តើកុមារអាចមើលរឿងអាសអាភាសតាមរបៀបណាខ្លះ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីក្មេងស្រី និងក្មេងប្រុស ដែលមិនត្រូវបានផ្ដល់ភាពថ្លៃថ្នូរក្នុងរឿងអាសអាភាស ដែលអាចធ្វើឲ្យយើងមានអារម្មណ៍អាក្រក់អំពីខ្លួនឯង ហើយក៏អាចធ្វើឲ្យយើងមើល និងគិតពីរាងកាយរបស់អ្នកដទៃ តាមរបៀបមិនល្អផងដែរ។**



# រូបភាពទី ៨៖



**សាច់រឿង៖** ទោះបីជា ចាន់ត្រាបានស្ដាប់លឺអំពីគ្រោះថ្នាក់នៃការមើលរឿងអាសអាភាសហើយ ក៏ដោយ ក៏គាត់នៅតែទៅផ្ទះមិត្តភ័ក្តរបស់គាត់ ដើម្បីមើលវីដេអូអាសអាភាស។

## សំនួរពិភាក្សា

1. ហេតុអ្វីបានជាចាន់ត្រានៅតែមើលរឿងអាសអាភាស ទោះបីជារិទ្ធបាននិយាយជាមួយគាត់រួចហើយ ?

## យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីសំពាធមិត្តភ័ក្ត។ ការយកឈ្នះលើការញៀនរឿងអាសអាភាសត្រូវការពេលវេលា។**



## រូបភាពទី ៩៖



**សាច់រឿង៖** ដោយសារតែពួកគេចាប់ផ្តើមស្រវឹងស្រា ពួកគេក៏នាំគ្នានិយាយលេងសើចអំពីមនុស្ស ស្រីដែលពួកគេបានឃើញនៅក្នុងវីដេអូ រួចក៏និយាយអំពីមនុស្សស្រីដែលពួកគេ ស្គាល់។ ស្រាប់តែមានម្នាក់បាននិយាយទៅចាន់ត្រាថា «ប្អូនស្រីឯងស្អាតដែរតើ! អញ្ចឹងឯងម៉េចក៏មិនថតរូបនាងយកមកឲ្យយើងមើលមក»។

### សំនួរពិភាក្សា

1. តើមនុស្សប្រុសដែលមើលរឿងអាសអាភាស គិតយ៉ាងណាចំពោះមនុស្សស្រីដែលនៅក្នុងរូបអាសអាភាស?
2. តើប្អូនគិតថាវាជាជម្រើសត្រឹមត្រូវទេដែលរៀនអំពីផ្លូវភេទតាមរយៈរូបភាពអាសអាភាស?
3. តើប្អូនគិតថាចាន់ត្រានឹងធ្វើអ្វី?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីការគោរពចំពោះមនុស្សស្រី និងរបៀបដែលល្អប្រសើរក្នុងការរៀនអំពី ផ្លូវភេទ និងទំនាក់ទំនង (ឧទា. រៀនពីគ្រូបង្រៀន, ឪពុកម្តាយ)**



## រូបភាពទី ១០៖



**សាច់រឿង៖** ចាន់ត្រាហួសចិត្តហើយស្រែកថា «កុំនិយាយអំពីប្អូនស្រីយើងដូច្នេះ!» ហើយគាត់បានបោកតេលេទូរទស្សន៍ចោល។ ពួកគេបានឈ្លោះគ្នាយ៉ាងខ្លាំង។ ចាន់ត្រាក៏បានដឹង ខ្លួនថា ការមើលរូបភាពអាសអាភាសអាចនាំឲ្យមនុស្សធ្វើអ្វីដែលមិនល្អ ហើយចាន់ត្រា ក៏ត្រឡប់ទៅផ្ទះវិញ ទាំងមានអារម្មណ៍មួម៉ៅជាមួយមិត្តភ័ក្តរបស់គាត់។

### សំនួរពិភាក្សា

1. ហេតុអ្វីបានជាចាន់ត្រាខឹង?
2. តើគាត់នឹងត្រូវសម្រេចចិត្តយ៉ាងណា?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**ពិភាក្សាគ្នាអំពីចរិតលក្ខណៈនៃមិត្តភ័ក្តល្អ និងមិត្តភ័ក្តអាក្រក់។**



## រូបភាពទី ១១៖



**សាច់រឿង៖** នៅថ្ងៃបន្ទាប់ ចាន់ត្រាបានដឹងខ្លួនថាគាត់ និងមិត្តភ័ក្តរបស់គាត់បានធ្វើរឿងមិនល្អ។ ហើយគាត់មិនចង់គិតអំពីមនុស្សស្រីក្នុងផ្លូវមិនល្អទៀតទេ។ ចាន់ត្រាបានសន្យានឹង ណារីថា គាត់នឹងព្យាយាមឈប់មើលរឿងអាសអាភាសទៀតហើយ ដើម្បីឲ្យណារី សប្បាយចិត្ត។

### សំនួរពិភាក្សា

1. តើមានអ្វីជម្រុញទឹកចិត្តចាន់ត្រាឲ្យឈប់មើលរឿងអាសអាភាស ?
2. តើមានអ្វីខ្លះដែលនឹងជួយឲ្យចាន់ត្រារក្សាពាក្យសន្យាជាមួយប្អូនស្រីរបស់គាត់ ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីការរៀនពីកំហុស ការចេះសុំទោស និងការស្វែងរកជំនួយ ដើម្បីឈប់មើលរឿងអាសអាភាស។**



## រូបភាពទី ១២៖



**សាច់រឿង៖** ចាន់ត្រាបានប្រាប់រិទ្ធអំពីរឿងដែលបានកើតឡើង ដែលធ្វើឲ្យគាត់មានអារម្មណ៍ស្លុត ចិត្ត។ រិទ្ធបានពន្យល់ប្រាប់ចាន់ត្រាថា ការមើលរឿងអាសអាភាសអាចធ្វើឲ្យយើង ញៀន ហើយ មានមនុស្សអាក្រក់មួយចំនួនដែលបោកប្រាស់ គំរាមកំហែង ឬ បង្ខំឲ្យ ក្មេងស្រី និងក្មេង ប្រុសថតរូបអាសអាភាសដែរ។ ចាន់ត្រាជឿសម្ដីរបស់រិទ្ធ ហើយ និយាយថា <<កាលពីមុន មិនដែលមានអ្នកណាប្រាប់ខ្ញុំអំពីបញ្ហារឿងអាសអាភាស និងអំពីផ្លូវភេទទេ។ ប្រហែលជាពួក យើងត្រូវសួរប៉ា ឬ អ្នកណាផ្សេងអំពីរឿងនេះហើយ ?>>

### សំនួរពិភាក្សា

1. តើចាន់ត្រាមានភាពរឹងមាំអាចឈប់មើលរឿងអាសអាភាសបានដោយរបៀបណា ?
2.. តើមានអ្នកណាទៀតដែលអាចជួយចាន់ត្រាឲ្យរឹងមាំបាន ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីការជួយលើកទឹកចិត្តមិត្តភ័ក្ត ដែលកំពុងជួបបញ្ហា និងការប្តេជ្ញាជួយគ្នាទៅវិញទៅមក។ និយាយអំពីអត្ថន័យនៃ "ភាពរឹងមាំ" ក្នុងស្ថានភាពនេះ។**



# រូបភាពទី ១៣៖



**សាច់រឿង៖** ចាន់ត្រាទើបតែងូតទឹករួច ដើម្បីចូលគេង។ ហើយគាត់ក៏មើលទៅទូរស័ព្ទរបស់គាត់។ គាត់នឹកឃើញថា ឥឡូវគាត់នៅតែម្នាក់ឯង ហើយទោះបីជាគាត់មើលរឿងអាសអាភាស ក៏គ្មានអ្នកណាឃើញគាត់ដែរ។ តែចិត្តមួយទៀត គាត់ពិតជាចង់ឈប់មើលរឿងអាសអាភាស និងចង់មានសេរីភាពពីរឿងនេះ។

## សំនួរពិភាក្សា

1. តើចាន់ត្រាអាចជួយខ្លួនឯង ក្នុងស្ថានភាពនេះដោយរបៀបណា ?
2. ទោះបីជាមានបញ្ហាកើតឡើង និងទោះបីជាចាន់ត្រាបានទទួលការប្រៀនប្រដៅពីបងក៏ដោយ តើប្អូនគិតថាហេតុអ្វីបានជា ចាន់ត្រានៅតែចង់ត្រឡប់ទៅមើលរឿងអាសអាភាសទៀត ?

## យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីបញ្ហានៃការញៀនរឿងអាសអាភាស និងការប្តេជ្ញាយកឈ្នះ ( ឧទា. ស្វែងរកជំនួយ, ទូរស័ព្ទទៅលេខទូរស័ព្ទជំនួយកុមារ ១២៨០ )**



# រូបភាពទី ១៤៖



**សាច់រឿង៖** ទោះបីជាគាត់មានអារម្មណ៍តានតឹង តែគាត់នៅចាំពាក្យសន្យារបស់គាត់ជាមួយប្អូនស្រី និងចងចាំដំបូន្មានរបស់រិទ្ធ។ ចាន់ត្រាដឹងថាការសម្រេចចិត្តរបស់គាត់មិនគ្រាន់តែសំរាប់គាត់ប៉ុណ្ណោះទេ ប៉ុន្តែសំរាប់គ្រួសារគាត់ផងដែរ។ ចាន់ត្រាព្យាយាមទប់ចិត្ត ខ្លួនឯង ហើយបិទទូរស័ព្ទរបស់គាត់ និងព្យាយាមចូលគេង។

## សំនួរពិភាក្សា

1. ចាន់ត្រាដឹងថាការសម្រេចចិត្តរបស់គាត់មិនគ្រាន់តែប៉ះពាល់ដល់គាត់ប៉ុណ្ណោះទេ តែប៉ះពាល់ដល់អ្នកដទៃផងដែរ។ តើប្អូន នឹងគិតដល់អ្នកណា នៅពេលប្អូនជួប ស្ថានភាពតានតឹងដូចចាន់ត្រា ?
2. តើមានអ្វីផ្សេងទៀតដែលអាចជួយចាន់ត្រាឲ្យឈប់គិតអំពីរឿងអាសអាភាស ?

## យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីមនុស្សប្រាំនាក់ដែលប្អូនស្រឡាញ់ និងយកចិត្តទុកដាក់**



## រូបភាពទី ១៥៖



**សាច់រឿង៖** ចាន់ត្រាបានគិតអំពីមនុស្សដែលចង់ទៅជួប ដើម្បីនិយាយអំពីបញ្ហារបស់ខ្លួន ហើយគាត់បានគិតថា ពូរបស់គាត់គឺជាមនុស្សដែលមានសុវត្ថិភាពសំរាប់គាត់។

### សំនួរពិភាក្សា

1. តើប្អូននឹងនិយាយជាមួយនរណាអំពីបញ្ហានេះ ប្រសិនបើប្អូនគឺជាចាន់ត្រា?

### យោបល់សម្រាប់អ្នកសម្របសម្រួល

និយាយអំពីបុគ្គលិកលក្ខណៈរបស់មនុស្សដែលមានសុវត្ថិភាព (ឧទា. គួរឲ្យទុកចិត្ត, យកចិត្តទុកដាក់, គួរឲ្យគោរព, មានពេលសំរាប់យើង, ជួយគាំទ្រ)



## រូបភាពទី ១៦៖



**សាច់រឿង៖** ទោះបីជាវាមិនងាយស្រួលក៏ដោយ តែដោយសារមានអ្នកជួយគាត់ ដូច្នេះចាន់ត្រាអាចឈប់មើលរឿងអាសអាភាសបាន ហើយចាប់ផ្តើមរៀនពូកែឡើងវិញ និងចូលរួមសកម្មភាពផ្សេងៗជាមួយគ្រួសារ និងមិត្តភ័ក្តរបស់គាត់។

### សំនួរពិភាក្សា

1. ឥឡូវនេះ ចាន់ត្រាមានសេរីភាព និងរីករាយនៅក្នុងជីវិត ដោយគ្មានការរំខានអារម្មណ៍។ តើមានអ្វីខ្លះដែលធ្វើឲ្យប្អូនសប្បាយរីករាយនៅក្នុងជីវិត?
2. តើប្អូនមានក្តីស្រម៉ៃអ្វី? ហើយតើប្អូនត្រូវធ្វើអ្វីខ្លះ ដើម្បីសម្រេចក្តីស្រម៉ៃនោះ? តើប្អូនត្រូវការជំនួយអ្វីខ្លះ ដើម្បីឈានទៅសម្រេចក្តីស្រម៉ៃនោះ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**លើកទឹកចិត្តកុមារឲ្យព្យាយាមសំរេចក្តីស្រម៉ៃ សំរាប់អនាគតរបស់ពួកគេ (ឧទា. សុំឲ្យកុមារគូររូបអំពីអ្វីដែលពួកគេចង់ធ្វើនៅថ្ងៃអនាគត)**



## រូបភាពទី ១៧៖



**សាច់រឿង៖** តាមរយៈបទពិសោធន៍ និងសេរីភាពដែលគាត់មាន ចាន់ត្រាក៏អាចជួយក្មេងប្រុសៗដទៃទៀតឲ្យរឹងមាំ និងឈប់មើលរឿងអាសអាភាសផងដែរ។

### សំនួរពិភាក្សា

1. ការលំបាកដែលចាន់ត្រាបានឆ្លងកាត់ អាចយកមកប្រើដើម្បីជួយអ្នកដទៃបាន។ តើប្អូនគិតថា ចាន់ត្រានឹងនិយាយអ្វីទៅកាន់ក្មេងប្រុសៗទាំងនេះ ?
2. តើប្អូនរៀនបានអ្វីខ្លះពីសាច់រឿងរបស់ចាន់ត្រា ដែលសំខាន់បំផុតសំរាប់ប្អូន ?

### យោបល់សម្រាប់អ្នកសម្របសម្រួល

**និយាយអំពីសារៈសំខាន់នៃការជួយមិត្តភ័ក្ត របស់អ្នក នៅពេលពួកគេកំពុងជួបប្រទះបញ្ហា**



# ខ្លឹមសារគន្លឹះ

១. ខ្ញុំជ្រើសរើសទទួលស្គាល់ថា រឿងអាសអាភាសបំផ្លាញ ហើយខ្ញុំចៀសវាង ឬ ឈប់មើលវា

២. ខ្ញុំជ្រើសរើសលើកទឹកចិត្ត និងជួយមិត្តភ័ក្តរបស់ខ្ញុំឲ្យធ្វើដូចខ្ញុំដែរ

៣. ខ្ញុំជ្រើសរើសប្រើប្រាស់ពេលវេលា និងលុយរបស់ខ្ញុំ ដោយភាពវៃឆ្លាត

៤. ខ្ញុំជ្រើសរើសរៀនអំពីរឿងផ្លូវភេទ តាមរបៀបដែលត្រឹមត្រូវ

៥. ខ្ញុំជ្រើសរើសអនាគតដែលល្អសំរាប់ខ្លួនខ្ញុំ និងមិត្តភ័ក្តខ្ញុំ